ក

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៥ ស្តីពី ការតែងតាំង ឯកឧត្តម លី ស៊ីណា ជាជំនួយការឯកឧត្តម សុន គន្ធរ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីមានឋានៈ ស្មើ អគ្គនាយក ១០៨២៦

២៣.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៦ ស្តីពី ការតែងតាំង ឯកឧត្តម ចាន់ យុត្ថា ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងធនធានទឹក និង ឧតុនិយម ១០៨២៧

២៣.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៧ ស្តីពី ការតែងតាំង ឯកឧត្តម ចំនួន ០២ រូប ជាអគ្គលេខាធិការ និងអគ្គលេខាធិការដ្ឋានរង នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ១០៨២៨

២៣.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះឯកឧត្តម ឌួង រតនា ១០៨២៩

២៣.១១.២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១២៩៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក វិចឆ៍យ អ៊ុងរតនាផល (WICHAI ONGRATANAPHOL) ជនជាតិថៃ សញ្ជាតិថៃ កើតនៅ ទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ១០៨៣០

២៦-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០១ ស្តីពី ការប្តូរ និងតម្លើង ប្រភេទក្របខ័ណ្ឌ ស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ០៤ រូប ១០៨៣១

២៦-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០២ ស្តីពី ការតែងតាំង ឯកឧត្តម គង់ សុផាត ជាទីប្រឹក្សាអមក្រសួង ផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១០៨៣២

២៦-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៣ ស្តីពី ការតែងតាំង ឯកឧត្តម គឹម សុខុន ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ១០៨៣៣

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៤ ស្តីពី ការតែងតាំង ឯកឧត្តម ណា ម៉ារឌី ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី ១០៨៣៤

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៥ ស្តីពី ការតែងតាំង ឯកឧត្តម សៅ ខលត្ថុណ៍ និង លោក ស៊ុខ ម៉ារី ជា ឧកញ៉ា ១០៨៣៥

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៦ ស្តីពី ការតែងតាំង មន្ត្រីរាជការ ចំនួន ០៣ រូប ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អគ្គនាយក ១០៨៣៦

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៧ ស្តីពី ការប្តូរប្រភេទក្របខណ្ឌតាមការប្រឡងប្រជែង ជូនមន្ត្រីរាជការចំនួន ៨៥ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងធនធានទឹក និងឧតុនិយម ១០៨៣៧

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ ចំនួន ១៦ រូប របស់ក្រសួងចំនួន ០៧ ១០៨៤២

២៩-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣០៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ហាក់គូ** (LEE HAK KU) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតខេត្តយ៉ុងស៊ី សាធារណរដ្ឋកូរ៉េ ១០៨៤៥

២៩-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាត់ថាណាស៊ីរិនុគុល ប្រាសត្ថាផន** (WATTANASIRINUKUL SATHAPHORN) ជនជាតិថៃ សញ្ជាតិថៃ កើតនៅខេត្តអង្គរសុវណ្ណ ព្រះរាជាណាចក្រថៃឡង់ដ៍ ដោយប្តូរឈ្មោះជា **លី បូស័ក្ត** (LEE BOSAK) ១០៨៤៦

២៩-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ័ង ឈីហ័រ** (WANG QIHUA) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ហ័ង អានតូនី** (WANG AN TONY) ១០៨៤៧

២៩-១១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គុយ វ៉េនប៊ីន** (CUI WENBIN) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តសានស៊ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **លី ចុងហួរ** (LI ZHONG HUA) ១០៨៤៨

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេនា ចំពោះឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ ឥណា** ១០៨៤៩

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះលោកជំទាវ ព្រះសង្ឃ មហាឧបាសក និង លោក ចំនួន ០៤ អង្គ/រូប ១០៨៥០

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា លោកជំទាវ ព្រះសង្ឃ និង អស់លោក ចំនួន ០៨ អង្គ/រូប ១០៨៥១

២៩-១១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១១១៣/១៣១៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះលោកជំទាវ និង លោកស្រី ចំនួន ០២ រូប ១០៨៥២

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

២០.១២.២០១៣ -អនុក្រឹត្យលេខ ៥៦៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០៨៥៣
២៣.១២.២០១៣ -អនុក្រឹត្យលេខ ៥៦៧ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ១០៨៥៦
២៣.១២.២០១៣ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.បក ស្តីពី ការផ្តល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ ១០៨៥៨
២៣.១២.២០១៣ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ៨ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ៦៨ អនក្រ. ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា ១០៨៦០
២៣.១២.២០១៣ -អនុក្រឹត្យលេខ ៥៧០ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១០៨៦២
២៣.១២.២០១៣ -អនុក្រឹត្យលេខ ៥៧១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០៨៧០
២៤.១២.២០១៣ -អនុក្រឹត្យលេខ ៥៧២ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៩០៧,៦៣ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះកាត់ចេញពី (១) ដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៦៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៨៧២
២៤-១២-២០១៣-អនុក្រឹត្យលេខ ៥៧៣ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៣០៥,៣២ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះកាត់ចេញពី (១) ដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១០៨៧៨
១១-១២-២០១៣-អនុក្រឹត្យលេខ ១១៦៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៨៨២
១១-១២-២០១៣-អនុក្រឹត្យលេខ ១១៦៥ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា ១០៩០៥
១១-១២-២០១៣-អនុក្រឹត្យលេខ ១១៦៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៩០៧
១១-១២-២០១៣-អនុក្រឹត្យលេខ ១១៦៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១០៩០៨

១៨-១២-២០១៣ -អនុក្រឹត្យលេខ ១១៦៨ អនក្រ.តត ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ ១០៩១០
១៨-១២-២០១៣ -អនុក្រឹត្យលេខ ១១៦៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៩១២

III_ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៨-១១-២០១៣-ប្រកាសលេខ ១១២០ សហវ. ស្តីពី ការបង្វែរឥណទានជូនខេត្តសៀមរាប សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៩១៣
០៨-១១-២០១៣-ប្រកាសលេខ ១១២១ សហវ. ស្តីពី ការបង្វែរឥណទានជូនរដ្ឋបាលក្រុង ស្រុក នៃខេត្តកំពង់ធំ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៩១៥
០៨-១១-២០១៣-ប្រកាសលេខ ១១២២ សហវ. ស្តីពី ការបង្វែរឥណទានជូនរដ្ឋបាលក្រុង ស្រុក នៃខេត្តបាត់ដំបង សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ ១០៩១៩
០៨-១១-២០១៣-ប្រកាសលេខ ១១២៣ សហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៩២៧
០៨-១១-២០១៣-ប្រកាសលេខ ១១២៤ សហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៩៣០
០៨-១១-២០១៣-ប្រកាសលេខ ១១២៥ សហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៩៣២
០៨-១១-២០១៣-ប្រកាសលេខ ១១២៦ សហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៩៣៤
០៨-១១-២០១៣-ប្រកាសលេខ ១១២៧ សហវ.អថ ស្តីពី ការធ្វើនិយ័តកម្មឥណទានថវិកា ១០៩៣៦

២_ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៥-១១-២០១៣-ប្រកាសលេខ ៩២៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហួណាន អឺរ-កាង (ខេមបូឌា) អ៊ិនវេសមេន បង្កើតរោងចក្រផលិត ម្សៅមី ,អាល់កុល, អាស៊ីតស៊ីទ្រិច ១០៩៣៨
២០-១១-២០១៣-ប្រកាសលេខ ៩៣៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដុងគ័ន ស៊ីធី ហ្វាញស្តារ ព្រីនធីង (ខេមបូឌា) បង្កើតរោងចក្រផលិត បោះពុម្ពលើសម្លៀកបំពាក់, បោះពុម្ពលើកេសកាតុង ១០៩៤២

<u>បញ្ជាក់</u> : ព្រះរាជក្រម, ព្រះរាជក្រឹត្យ, អនុក្រឹត្យ ឆ្នាំ ២០១៣ នឹងមានចុះផ្សាយក្នុងរាជកិច្ចដើមឆ្នាំ ២០១៤ បន្តទៀត ។

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហិភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **លី ស៊ីណា** ជាជំនួយការឯកឧត្តម **សុន គន្ធរ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៥-១៣១១-១៣០៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៦៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៤៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **ចាន់ យុត្ថា** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងធនធានទឹក និងឧតុនិយម ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១៣១១-១៣១០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ១២៥៧ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង៖

១-ឯកឧត្តម **ម៉ែល តូនី** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប មានឋានៈស្មើអនុរដ្ឋលេខាធិការ ជំនួសឯកឧត្តម **ចាន់ យុត្ថា** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

២-ឯកឧត្តម **ខូច មាស** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប មានឋានៈស្មើអគ្គនាយក ជំនួសឯកឧត្តម **សៅ វណ្ណសិរីវុទ្ធ** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.១៣១១ - ១៣១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៦៦ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ឌួង រតនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ករណ. ១៣១១-១៣១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៧៨ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១២៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វិច្ឆ័យ អ៊ុងរតនាផល** (WICHAI ONG-RATANAPHOL) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី០២ ខែមករា ឆ្នាំ១៩៦៨ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៩. ១៣១១. ១៣១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ១២៣៥/ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ប្តូរ និងតម្លើង ប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការ ចំនួន ០៤ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាករណីពិសេស នៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល :

១-លោក	**មិញ ជីវតុង**	ពីនាយក្រមការ ថ្នាក់លេខ ៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១០
២-លោក	**តែ វណ្ណសុជា**	ពីក្រមការ ថ្នាក់លេខ ១៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣-លោក	**គង់ មករា**	ពីក្រមការ ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤-លោក	**សាន់ ដារិទ្ធ**	ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស. ១៣១១. ១៣១៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ១២៨៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **គង់ សុផាត** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស. ១៣១១-១៣១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ: ១២៧៣ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **គឹម សុខុន** ជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ករណ.១៣១១-១៣១៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៨២ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រត្នត្តយក្សត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ណោ ម៉ារឌី** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស. ១៣១១. ១៣១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១៣០០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

តែងតាំង :

១-ឯកឧត្តម សៅ ចលគួណ៌

២-លោក ស៊ីវ ម៉ារី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.១៣១១.១៣២០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៩០ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមន្ត្រីចំនួន ០៣រូប ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ **អគ្គនាយក** ៖

១- ឯកឧត្តម **អ៊ឹន ស៊ីម៉ាណាន់**

២- ឯកឧត្តម **ម៉ៅ ផល**

៣- ឯកឧត្តម **លី ចាន់សុភក្តិ**

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៣១១.១៣២១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៨៩ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ .ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៧០៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខន្តិកៈ ដោយឡែក នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ប្ដូរប្រភេទក្របខណ្ឌតាមការប្រឡងប្រជែង ជូនមន្ត្រីរាជការចំនួន៨៥ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងធនធានទឹក និងឧតុនិយម ៖

ល.រ	គោត្តនាម និង នាម	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ស្នើសុំ
១	លោកស្រី អោក សុមុន្នី	ពីក្រមការ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២	លោក ជន ណារ៉េត	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៦	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣	លោក ឃុន សាខឿន	ពីក្រមការ ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤	លោក [illegible] អ៊ា	ពីក្រមការ ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៥	លោក សាំនី សីលា	ពីក្រមការ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៦	លោក ញ៉ាញ់ ជាបហ៊ង	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៧	លោក លន ម៉ាគីលីន	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៧	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៨	លោក អ៊ាង ផល្គុន	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៩	លោក អ៊ុច ភ្លឹង	ពីក្រមការ ថ្នាក់លេខ ១១	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១០	លោក ជឹម ភិរម្យ	ពីក្រមការ ថ្នាក់លេខ ៧	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១១	លោក ទៀវ វុត្ថា	ពីក្រមការ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១២	លោក សួង ប៊ុនហោ	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៣	លោក ស៊ិន សេរី	ពីក្រមការដើមខ្សែ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៤	លោក សង់ វិសាល	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៥	លោក សួន សំអួន	ពីក្រមការ ថ្នាក់លេខ ៧	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៦	លោក សុក ចាន់ធឿន	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៧	កញ្ញា ឆាយ ភ័រី	ពីក្រមការ ថ្នាក់លេខ ១២	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៨	លោក មាន សេង	ពីក្រមការ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
១៩	លោក ខៃ សុជា	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២០	លោក យាង ប៉េងលាង	ពីក្រមការ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២១	លោកស្រី ប៊ុន ស៊ីជា	ពីក្រមការដើមខ្សែ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២២	លោក ហ៊ុយ ភ័ន់ថា	ពីក្រមការដើមខ្សែ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៣	លោក ឈឹម សាម៉ន	ពីក្រមការ ថ្នាក់លេខ ១១	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៤	លោកស្រី ញឹម សុភា	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៦	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៥	លោក សុខ វណ្ណថា	ពីក្រមការ ថ្នាក់លេខ ១២	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៦	លោក ថូ វុធ	ពីក្រមការ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៧	លោក មៅ រតន៍	ពីក្រមការ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៨	លោក ជា អនុជិត	ពីក្រមការ ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
២៩	លោក ខែម ភារម្យ	ពីនាយក្រមការ ថ្នាក់លេខ ៥	ទៅអនុមន្ត្រី ថ្នាក់លេខ ១២
៣០	លោកស្រី ស៊ឹម សុធារី	ពីក្រមការ ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣១	លោកស្រី ហ៊ិន ចន្ធូ	ពីក្រមការ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣២	លោក ហាញ់ វុឌ្ឍា	ពីក្រមការដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣៣	លោកស្រី ស៊ឹម សុខេម៉ា	ពីក្រមការ ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣៤	លោកស្រី ជីព អ៊ាង	ពីក្រមការ ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣៥	លោក ម៉ម ប្រុស	ពីនាយក្រមការ ថ្នាក់លេខ ៣	ទៅអនុមន្ត្រី ថ្នាក់លេខ ៨
៣៦	លោក សៅ សម្ផស្ស	ពីនាយក្រមការ ថ្នាក់លេខ ៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១០
៣៧	លោក កឹម ចំរើន	ពីក្រមការ ថ្នាក់លេខ ១១	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣៨	[illegible] ទឹក ទ្រី	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៣៩	លោក [illegible] កុយ	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤០	លោក អ៊ុំ ប៊ុនធា	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤

២/៥

៤១	លោកស្រី សុខ ស្រីពៅ	ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤២	លោកស្រី បូ វណ្ណារី	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១០	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៣	លោក អ៊ឹក សុផល	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៤	លោក អ៊ិត ស៊ីថន	ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៥	លោកស្រី ស្រេង ទៀង	ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៦	លោក លី ស៊ុនប៊ុណ្ណរិទ្ធ	ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ១២	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៧	លោក ឡែម សំអាត	ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ៤	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៨	លោក អេង ជួរ	ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ៣	ទៅអនុមន្ត្រី ថ្នាក់លេខ ១៤
៤៩	លោក អ៊ិត តារា	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥០	លោក ហេង លីម	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១២	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥១	លោក ចាន់ ផាន់ណា	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១២	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥២	លោក ទេព កោសល្យ	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៣	លោក បូរ ណុចរ័ត្ន	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១០	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៤	លោក សៀម នី	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៥	លោក ប្រាក់ ឡាក់	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៦	លោក ម៉ុន សាម៉ន	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៧	លោក ហៃ ប៊ុនធឿន	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៦	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៨	លោក សឿង សុថា	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៧	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៥៩	លោកស្រី ពេជ ម៉ាលី	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៥	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦០	លោក មាស សារឿន	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៧	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
[illegible]	[illegible] ាប រិទ្ធី	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
[illegible]	លោក [illegible] ធុរៈ	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១០	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៦៣	លោក ជុំ សំបុក	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦៤	លោក មៅ ផល្លែន	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦៥	លោក អ៊ុច ហ៊ីង	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៦	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦៦	លោកស្រី សួស ចិន្តា	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦៧	លោក ហូ គឹមវន់	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦៨	លោក អ៊ឹម សួស្តី	ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៦៩	លោក សូ ផល្លី	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧០	លោក សាត ដាក៉ា	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៣	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧១	លោក គឹ សម្បត្តិ	ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧២	លោក សៅ ចន្ទណារិទ្ធ	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧៣	លោក ជាន់ លីតឹក	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧៤	លោក ហ៊ិន លីសេង	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧៥	លោក ជាស យឹម	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៧	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧៦	លោក សាន់ លាងឃីម	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៣	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧៧	លោក តេង គុងហេង	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៧	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៧៨	លោកស្រី សុង ច័ន្ទពិសី	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
[illegible]	លោកស្រី ឡាំ សោភ័ណ	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៧	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៨០	លោក កង សារឿន	ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៨១	លោក វង់ ឡូ	ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១១	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៨២	លោក ឈឹម សុខហេង	ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១១	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៨៣	លោក ជុំ សុង	ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ ១៣	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៨៤	លោក ប៉ាង សុធារិទ្ធ	ពីភ្នាក់ងារបច្ចេកទេសបឋមថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤
៨៥	លោក ជាង វី	ពីភ្នាក់ងារបច្ចេកទេសបឋមថ្នាក់លេខ ១	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤

មាត្រា២.-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួល បន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចានស.១៣១១.១៣៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៩៤ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម ០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០២ រូប របស់ក្រសួងចំនួន ០២ ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងពីឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ទៅឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ៖

ល.រ	គោត្តនាម និង នាម	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
ក្រសួងពាណិជ្ជកម្ម			
១	ឯកឧត្តម **ខ៊ែត សុភិន**	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់			
១	ឯកឧត្តម **ជា ផលរី**	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ ៦

មាត្រា ២.- ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ០១ រូប របស់ក្រសួងយុត្តិធម៌ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ តទៅ ៖

ល.រ	គោត្តនាម និង នាម	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	ឯកឧត្តម **អ៊ុំ ប៊ុនឡើង**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣

មាត្រា ៣.- ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ០៨ រូប របស់ក្រសួងចំនួន ០៣ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ តទៅ ៖

ល.រ	គោត្តនាម និង នាម	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ			
១	ឯកឧត្តម **ច័ន្ទ វណ្ណា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
ក្រសួងព័ត៌មាន			
១	ឯកឧត្តម **តន់ យ៉ាន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១
២	ឯកឧត្តម **សាន សំបូរី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣	ឯកឧត្តម **គី ឡុង**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤	ឯកឧត្តម **ហាស់ សំអាត**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៥	ឯកឧត្តម **ឈាន លាង**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
ក្រសួងទេសចរណ៍			
១	ឯកឧត្តម **សៀង គឹមហាន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
[illegible]	ឯកឧត្តម **និត ចន្ថា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥

មាត្រា ៤.- ដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០៥ រូប របស់ក្រសួងចំនួន ០២ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៖

ល.រ	គោត្តនាម និងនាម	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
ក្រសួងទេសចរណ៍			
១	ឯកឧត្តម **ប៉ាក់ សុខុម**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
២	ឯកឧត្តម **ហោ សារុន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣	លោកជំទាវ **សម មុន្នីកា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤	ឯកឧត្តម **ឌួង ធីរៈ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
ក្រសួងមុខងារសាធារណៈ			
១	ឯកឧត្តម **ជុក មុន្នី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២

មាត្រា ៥.- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.១១១៣.១៧២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៩៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ហាក់គូ** (LEE HAK KU) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥០ នៅខេត្តយ៉ាំងស៊ី សាធារណរដ្ឋកូរ៉េ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.១៣១១.១៣២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១២៩៧ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៣១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **វ៉ាត់ថាណាស៊ិរិនុគល់ ស្រាសត្ថាផន** (WATTANASIRINUKUL SATHAPORN) ជនជាតិថៃ សញ្ញាតិថៃ កើតថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៨៣ នៅខេត្តអង្គសុវណ្ណ ព្រះរាជាណាចក្រថៃឡង់ដ៍ ដោយប្តូរឈ្មោះជា **លី បូស័ក្ក** (LEE BOSAK)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧ រស. ១៣១១. ១៣២៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៩៤ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ឈីហ័រ** (WANG QIHUA) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៦៧ នៅខេត្តឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **វ៉ាង អានតូនី** (WANG AN TONY)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ល. ១៣១១. ១៣២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៩៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គុយ វ៉េនប៊ីន** (CUI WENBIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៨០ នៅខេត្តសានស៊ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **លី ចុងហួរ** (LI ZHONG HUA)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣៩៧. ១៣១១. ១៣២៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ១២៩៦ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ ភាព**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

១៣៧ព.១៣១១.១៣២៥

លេខ:១២៩១ស.ណ
សំណៅចែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

លោកជំទាវ មាស ស៊ុថន

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ព្រះតេជគុណអច្ចិន្ទវីរិយោ នាង ថេម ២-មហាឧបាសក ណៅ ជឹម

៣-លោក ដួង ទ៉ាន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរស.១៣១១.១៣២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១២៩៣ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

ឧកញ៉ា **ជា ធី**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-ព្រះតេជគុណ **ហែម ឡូត**
២-លោក **តែ គៀតហ៊ុយ**
៣-លោក **តាន់ អេងចោ**
៤-លោកជំទាវ **អ៊ូ សិរីវី**

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១-ព្រះតេជគុណសិរីមុនី **ប៊ូ ចាន់ស៊ីណា**
២-ព្រះតេជគុណវិសាលសីលគុណ **ម៉ី សុធី**
៣-លោក **អៀន លាវ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៧. ១៣១១.១៣៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ៦២៨៨ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១៣១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

លោកស្រី អ៊ុំ លីគៀង

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

លោកជំទាវ ឆេព សុវណ្ណី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១៣១១. ១៣៣១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៩២ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣ /០១៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានអនុញ្ញាតឲ្យធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

ក-និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែក)

ឯកតា លានរៀល

ជំពូក	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ	ឥណទានថ្មីមុននិយ័តកម្ម	និយ័តកម្ម		ឥណទានថ្មីក្រោយនិយ័តកម្ម
				កើន	ថយ	
	និយ័តកម្មចេញ					
	៩៩- ចំណាយមិនទាន់បែងចែក				1 464 032	
៦៦	បន្ទុកហិរញ្ញវត្ថុ	230 877	230 877	-	230 877	0
៦៥	ឧបត្ថម្ភក្រុង ស្រុកនិងឃុំ សង្កាត់	375 326	375 326	-	305 056	70 270
៦៥	ចំណាយចរន្តក្នុងការអនុវត្តគម្រោង	150 000	150 000	-	20 000	130 000
០៩	ចំណាយមិនបានគ្រោងទុក	651 050	651 050	-	502 250	148 800
១៦	ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល	330 924	330 924	-	330 924	0
២៧	អចលកម្មហិរញ្ញវត្ថុផ្សេងៗ	74 925	74 925	-	74 925	0
	និយ័តកម្មចូល			1 464 032		
	១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ			1 001 782		
៦៦	បន្ទុកហិរញ្ញវត្ថុ	0	0	230 877	-	230 877
៦៥	ឧបត្ថម្ភក្រុង ស្រុកនិងឃុំ សង្កាត់	23 160	23 160	305 056	-	328 216
៦៣	ពន្ធនិងអាករ	131 400	131 400	60 000	-	191 400
១៦	ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល	0	0	330 924	-	330 924
២៧	អចលកម្មហិរញ្ញវត្ថុផ្សេងៗ	0	0	74 925	-	74 925
	១៣- ក្រសួងរ៉ែនិងថាមពល			192 250		
៦៥	ឧបត្ថម្ភកជននិងជំនួយសង្គម	223	223	192 250	-	192 473
	២៥- ក្រសួងសាធារណការនិងដឹកជញ្ជូន			250 000		
៦១	សេវាខាងក្រៅ	1 538	1 538	250 000	-	251 538
	២៨- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ (ថវិកាកម្មវិធី)			20 000		
៦៥	ឧបត្ថម្ភកជននិងជំនួយសង្គម	43 268	43 268	20 000	-	63 268

ខ-និយ័តកម្មចេញពីទីស្តីការគណៈរដ្ឋមន្ត្រី

ឯកតា លានរៀល

ជំពូក	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ	ឥណទានថ្មី មុន និយ័តកម្ម	និយ័តកម្ម		ឥណទានថ្មី ក្រោយ និយ័តកម្ម
				កើន	ថយ	
	និយ័តកម្មចេញ					
	០៥.១-ទីស្តីការគណៈរដ្ឋមន្ត្រី				500	
៦៥	ឧបត្ថម្ភកធននិងជំនួយសង្គម	161 645	161 645		500	161 145
	(អាជ្ញាធរប្រេងកាតជាតិកម្ពុជា)					
	និយ័តកម្មចូល					
	១៣-ក្រសួងរ៉ែនិងថាមពល			500		
៦៥	ឧបត្ថម្ភកធននិងជំនួយសង្គម	223	192 473	500	-	192 973

មាត្រា២.-

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៨ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស
- យោងតាមការចាំបាច់នៃការងារ

សម្រេច

មាត្រាមួយ .-

មាត្រា២នៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវបានធ្វើការកែសម្រួលដូចតទៅ ៖

មាត្រា ២ .-ថ្មី

សមាសភាពគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស មានដូចតទៅ ៖

១- អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធាន

២- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ	មួយរូប	អនុប្រធាន
៣- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	មួយរូប	សមាជិក
៤- រដ្ឋលេខាធិការក្រសួងការពារជាតិ	មួយរូប	សមាជិក
៥- អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	មួយរូប	សមាជិក
៦- ប្រធាននាយកដ្ឋានឥស្សរិយយសទីស្តីការគណៈរដ្ឋមន្ត្រី		លេខាធិការ។

សមាសភាពជាក់ស្តែងនៃគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយសត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រាពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបី .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ៨ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្តល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

លិខិតឆ្លងដែនធម្មតាដែលផ្តល់ជូនពលករ ពលការិនីខ្មែរទៅធ្វើការដោយស្របច្បាប់នៅបរទេស ត្រូវបង់អាករដូចពលរដ្ឋខ្មែរទូទៅ។

តម្លៃអាករលិខិតឆ្លងដែនធម្មតាដែលផ្តល់ជូនពលករ ពលការិនីខ្មែរ ត្រូវអនុវត្តតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា២.-

ត្រូវបានផ្តល់លិខិតឆ្លងដែនធម្មតា ជូនសិស្ស និស្សិតខ្មែរ ទទួលបានអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស ដោយអាករជាបន្ទុករបស់រដ្ឋ។

សំណើសុំផ្តល់លិខិតឆ្លងដែនធម្មតាសម្រាប់សិស្ស និស្សិតខ្មែរ ទទួលបានអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស ត្រូវមានការបញ្ជាក់ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៣.-

លិខិតឆ្លងដែនធម្មតាត្រូវផ្តល់ជូនពលករ ពលការិនី និង សិស្ស និស្សិតខ្មែរក្នុងរយៈពេលយ៉ាងយូរ ២០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

មាត្រា៤.-

អនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរទៅធ្វើការដោយស្របច្បាប់នៅបរទេស អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរទៅធ្វើការដោយស្របច្បាប់នៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៤តទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា ៨ និងមាត្រា ១០ នៃអនុក្រឹត្យ លេខ៦៨អនក្រ. ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រាមួយ.–

មាត្រា៨និងមាត្រា១០នៃអនុក្រឹត្យលេខ៦៨អនក្រ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៩៤ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួលដូចតទៅៈ

មាត្រា ៩._ថ្មី

លិខិតឆ្លងដែនធម្មតាផ្ដល់ជូនពលរដ្ឋខ្មែរ ទាំង២ភេទ សម្រាប់ធ្វើដំណើរទៅបរទេស។

ការផ្ដល់លិខិតឆ្លងដែនដល់កុមារអាយុក្រោម១៥ឆ្នាំ ត្រូវមានសំណើ ឬការអនុញ្ញាតជាលាយល័ក្ខអក្សរពីឪពុក ម្ដាយ ឬ អាណាព្យាបាល ដោយមានភ្ជាប់មកជាមួយ ឯកសារសម្គាល់គ្រួសារ និងសំបុត្រកំណើត។

មាត្រា១០._ថ្មី

លិខិតឆ្លងដែន ធម្មតាមានសុពលភាពរយៈពេល ០៥ឆ្នាំ សម្រាប់កុមារ មានអាយុពី ០ឆ្នាំ ដល់ អាយុ៥ឆ្នាំ និងមានសុពលភាពរយៈពេល ១០ឆ្នាំ សម្រាប់អ្នកដែលមានអាយុពី ៦ឆ្នាំ ឡើង។

មាត្រាពីរ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រាបី._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ៨ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពី ការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៣

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១: អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

ជំពូកទី ២
តួនាទី និងភារកិច្ច

មាត្រា ២: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានប្រធានដឹកនាំរួម និងមានអនុប្រធាន ព្រមទាំងសមាជិកជាជំនួយការរបស់ប្រធាន ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

មាត្រា ៣: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលមានអក្សរកាត់ គ.ស.ម.ក មានភារកិច្ច ៖

- ការពារ លើកស្ទួយ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្សនិងពាក្យបណ្តឹងតវ៉ានានា
- ស្រាវជ្រាវអង្កេតករណីនានា ឬធ្វើការវាយតម្លៃការស្រាវជ្រាវអង្កេតរបស់សមត្ថកិច្ច ឬសហការស្រាវជ្រាវអង្កេតជាមួយសមត្ថកិច្ច ហើយធ្វើសំណុំឯកសារ ផ្សព្វផ្សាយ ជូនសាធារណៈជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ និងជូនសមត្ថកិច្ចនោះវិញ
- ចុះត្រួតពិនិត្យតាមមូលដ្ឋាននានា ដើម្បីធ្វើការវាយតម្លៃនិងផ្តល់ឱវាទអំពីសិទ្ធិមនុស្ស
- អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាសាធារណៈនិងតាមមុខសញ្ញានីមួយៗ
- កសាងភ្នាក់ងារ និងមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្តរបស់ខ្លួននៅតាមស្ថាប័នរដ្ឋ ឯកជន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ
- ផ្តល់យោបល់និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលំអនិងធ្វើយ៉ាងណាឲ្យស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ
- លើកមតិនិងចូលរួមមតិក្នុងការកែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាល
- ចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនិងចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ដែលពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស
- សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលជាស្ថាប័នទទួលខុសត្រូវលើសិទ្ធិកុមារនិងសិទ្ធិនារី និងស្ថាប័នសិទ្ធិមនុស្សនានារបស់រដ្ឋដើម្បីជម្រុញការអភិវឌ្ឍសិទ្ធិមនុស្សតាមផ្នែកនិមួយៗឲ្យបានល្អ
- ជួយដល់រាជរដ្ឋាភិបាលជំរុញការងារនីតិរដ្ឋនិងការបណ្តុះបណ្តាលអ្នកច្បាប់ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស
- ក្នុងនាមរាជរដ្ឋាភិបាលផ្តល់សេវាប្រឹក្សាច្បាប់និងផ្តល់មេធាវីជួយការពារក្តីដល់ជនក្រីក្របូអ្នកដែលត្រូវមេធាវីទាំងឡាយបដិសេធមិនព្រមទទួលការពារក្តី
- គាំទ្រ សហការជាមួយក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុការពារ និង

អភិវឌ្ឍវិស័យសិទ្ធិមនុស្សនៅកម្ពុជា

- រៀបចំរបាយការណ៍ជាតិជូនរាជរដ្ឋាភិបាលស្តីពីការអនុវត្តលិខិតបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធទៅនឹងវិស័យសិទ្ធិមនុស្ស និងរបាយការណ៍បំភ្លឺនានាសម្រាប់សាធារណមតិជាតិនិងអន្តរជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា ៤: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ប្រជុំរាល់ ០៦ខែម្តង តាមការអញ្ជើញរបស់ប្រធាន ដើម្បីត្រួតពិនិត្យវាយតម្លៃការងារ និងលើកទិសដៅការងារ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រៀបចំសន្និបាតទូទាំងប្រទេស ០២ឆ្នាំម្តង ដើម្បីវាយតម្លៃស្ថានភាពសិទ្ធិមនុស្ស និងលើកសំណូមពរអភិវឌ្ឍន៍ជាបន្ត ។ របាយការណ៍របស់សន្និបាត ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥: ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ធ្វើការតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យការងារសិទ្ធិមនុស្សកម្ពុជា ។

ជំពូកទី ៣
រចនាសម្ព័ន្ធ

មាត្រា ៦: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មាន២ អគ្គនាយកដ្ឋាន ៖

១- អគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្តឹង : ទទួលការងារ រដ្ឋបាល ហិរញ្ញវត្ថុ គ្រប់គ្រង និងសេវានានា បំរើឱ្យគណៈកម្មាធិការ ទំនាក់ទំនងសាធារណៈ ទំនាក់ទំនងសិទ្ធិមនុស្សក្នុងប្រទេស និងក្រៅប្រទេស ពាក្យបណ្តឹងតវ៉ា រៀបចំបណ្តាញ និងបណ្តុះបណ្តាលមន្ត្រីឃ្លាំមើលសិទ្ធិមនុស្ស ពិសេសលើកទឹកចិត្តដោះស្រាយទំនាស់តាមរបៀបសម្រុះសម្រួល ។

២- អគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស : ទទួលការងារបច្ចេកទេសពាក់ពន្ធ័លើការស្រាវជ្រាវ ប្រមូលពត៌មាន ឯកសារ ធ្វើរបាយការណ៍ពីបទរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់ និងទទួលការងារធ្វើរបាយការណ៍តាមផ្នែកនីមួយៗ នៃអនុសញ្ញាអន្តរជាតិ បណ្តុះបណ្តាលអប់រំផ្សព្វផ្សាយសិទ្ធិមនុស្ស រៀបចំវេទិកាសាធារណៈមតិ និងបើកលទ្ធភាពឱ្យមានការសួរដេញដោលដោយសេរី ។

មាត្រា ៧: មន្ត្រី បុគ្គលិកបំពេញការងារក្នុងស្ថាប័ននេះ ជាមន្ត្រីបុគ្គលិករាជការដែលមានក្របខណ្ឌស្រាប់ ឬក្របខ័ណ្ឌដែលស្ថាប័នមុខងារសាធារណៈជាអ្នកផ្តល់មកឱ្យ ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចទទួលបាននូវអ្នកស្ម័គ្រចិត្តមួយចំនួន ដែលពុំយកប្រាក់បៀវត្សពីរដ្ឋអោយធ្វើជាទីប្រឹក្សា និងអ្នកជំនាញ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចស្នើតែងតាំងទីប្រឹក្សា និងអ្នកជំនាញការខ្មែរ និងបរទេសអមគណៈកម្មាធិការដើម្បីជួយសិក្សា និងផ្តល់យោបល់ពីការងារជំនាញនីមួយៗ ។ ទីប្រឹក្សា និងអ្នកជំនាញការខ្មែរអាចមានឋានៈពីប្រធាននាយកដ្ឋានឡើងទៅ ។

ជំពូកទី ៤
ប្រភពធនធាន

មាត្រា ៨: រាជរដ្ឋាភិបាលមានភារកិច្ចផ្តល់មធ្យោបាយការងារ ថវិកាសំរាប់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចបំពេញការងាររបស់ខ្លួនបានល្អ ។ ថវិការបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ជំពូកទី ៥
អំពីរូបសញ្ញា និងត្រា

មាត្រា ៩: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានរូបសញ្ញា និងត្រាផ្ទាល់របស់ខ្លួន ។

មាត្រា ១០: តួនាទី ភារកិច្ច រូបសញ្ញា និងត្រារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាត្រូវកំណត់ក្នុងអនុក្រឹត្យដោយឡែក ។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

មាត្រា ១១: ព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៦៣ ចុះថ្ងៃ ទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត /០១០០/០០៨ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

- សម្របសម្រួល សហការ និងផ្តល់យោបល់លើកិច្ចការសិទ្ធិមនុស្សរបស់អង្គការសិទ្ធិមនុស្សក្នុងថ្នាក់តំបន់
- សិក្សាស្វែងយល់ពីយន្តការការពារសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកអាស៊ាននិងរបស់តំបន់នានា
- ធ្វើជាសេនាធិការឲ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងស្ថាប័នសិទ្ធិមនុស្សអាស៊ាននិងតំបន់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានសិទ្ធិមនុស្សតំបន់និងអាស៊ាន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

មាត្រា ៩: រចនាសម្ព័ន្ធថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

ជំពូកទី ៥
អគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស

មាត្រា ១០: អគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស ជាសេនាធិការឲ្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ទទួលបន្ទុកលើការងារបច្ចេកទេសពាក់ព័ន្ធនឹងការស្រាវជ្រាវ ប្រមូលព័ត៌មាននិងឯកសារ ធ្វើរបាយការណ៍ពីការរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់ កោសល្យវិច័យ ជំនាញនានា និងទទួលតាមផ្នែកនីមួយៗនៃអនុសញ្ញាអន្តរជាតិ បណ្តុះបណ្តាល អប់រំផ្សព្វផ្សាយ សិទ្ធិមនុស្ស ដោយរៀបចំជាវេទិកាសាធារណៈ។
អគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស មាននាយកដ្ឋានដូចតទៅ៖

- នាយកដ្ឋានស៊ើបអង្កេត
- នាយកដ្ឋានអប់រំសិទ្ធិមនុស្ស
- នាយកដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងអង្គការសហប្រជាជាតិ។

អគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួន តាមការចាំបាច់។

មាត្រា ១១: នាយកដ្ឋានស៊ើបអង្កេត មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ស៊ើបអង្កេត ត្រួតពិនិត្យ ស្រាវជ្រាវការរំលោភសិទ្ធិមនុស្សដោយខ្លួនឯង ឬដោយសហការស៊ើបអង្កេតជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអង្គការសង្គមស៊ីវិល លើករណីរំលោភសិទ្ធិមនុស្ស
- ត្រួតពិនិត្យវិស័យសិទ្ធិមនុស្សនៅតាមពន្ធនាគារ មណ្ឌលអប់រំកែប្រែ កន្លែងឃុំឃាំង និងមណ្ឌលស្តារនីតិសម្បទា

- ស្រាវជ្រាវប្រមូលព័ត៌មាន និងភស្តុងតាងពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សក្នុងគ្រប់រូបភាព
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីការពារសន្តិសុខនិងសុវត្ថិភាពជូនសាក្សីនិងជនរងគ្រោះ
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ អំពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានស៊ើបអង្កេត ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

មាត្រា ១២: នាយកដ្ឋានអប់រំសិទ្ធិមនុស្ស មានតួនាទីនិងភារកិច្ចដូចតទៅៈ

- រៀបចំកសាងផែនការយុទ្ធសាស្ត្រ និងនយោបាយស្តីពីកម្មវិធីសិក្សានិងវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស
- អប់រំ ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្សដល់អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត កម្មករ ប្រជាពលរដ្ឋ និងក្រុមជនជាតិភាគតិច
- សហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ចូលកម្មវិធីអប់រំ ដើម្បីយល់ដឹងអំពីសិទ្ធិមនុស្ស
- រៀបចំសិក្ខាសាលានិងរៀបចំវេទិកាសាធារណៈ
- រៀបចំនិងគ្រប់គ្រងកិច្ចការបណ្ណាល័យ បណ្ណសារ សម្រាប់សិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ អំពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានអប់រំសិទ្ធិមនុស្ស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

មាត្រា ១៣: នាយកដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងអង្គការសហប្រជាជាតិ មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ពិនិត្យព័ត៌មានដែលមានស្រាប់និងស្រាវជ្រាវព័ត៌មានបន្ថែមដូចជាច្បាប់ គោលនយោបាយ សារាចរណែនាំ សេចក្តីសម្រេច ការអនុវត្ត និងស្ថានភាពជាក់ស្តែងដែលពាក់ព័ន្ធទៅនឹងកតិកាសញ្ញា អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ
- រៀបចំសរសេររបាយការណ៍ស្តីពីការអនុវត្តលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស
- រៀបចំសរសេររបាយការណ៍ជាតិតាមកាលកំណត់

- សម្របសម្រួល សហការ និងផ្តល់យោបល់ លើកិច្ចការសិទ្ធិមនុស្ស ជាមួយអង្គការសហប្រជាជាតិនិងអង្គភាពសិទ្ធិមនុស្សនានា
- សម្របសម្រួល និងសហការជាមួយនាយកដ្ឋានតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីស្វែងរកទិន្នន័យថ្មីៗពាក់ព័ន្ធនឹងកតិកាសញ្ញា អនុសញ្ញា និងអនុសាសន៍នានារបស់អង្គការសហប្រជាជាតិបញ្ចូលទៅក្នុងរបាយការណ៍ជាតិ
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ អំពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងអង្គការសហប្រជាជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

មាត្រា ១៤: រចនាសម្ព័ន្ធថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

ជំពូកទី ៦
មន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្ត

មាត្រា ១៥: នៅតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្ត ដែលមានភារកិច្ចសម្របសម្រួល និងឃ្លាំមើលការអនុវត្តការងារសិទ្ធិមនុស្សនៅមូលដ្ឋាន តាមការណែនាំរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

មាត្រា ១៦: មន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្តត្រូវតែងតាំងដោយប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។

ជំពូកទី ៧
រូបសញ្ញា និងត្រាគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

មាត្រា ១៧: រូបសញ្ញាគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានរូបភាពដូចតទៅ៖

- រូបភូគោលពណ៌ទឹកសមុទ្រលាយពណ៌ស្វាយដែលមានទំរពណ៌ត្នោត តំណាងឲ្យទឹកដីជីវិត មនុស្ស សត្វ និងវត្ថុទាំងអស់ដែលមានអត្ថិភាពនៅក្នុងពិភពលោក
- រូបផែនទីប្រទេសកម្ពុជាពណ៌បៃតងខ្ចី នៅលើភូគោលតំណាងឲ្យប្រទេសកម្ពុជា មានឯករាជ្យនិងសេរីភាពពេញលេញក្នុងក្របខ័ណ្ឌពិភពលោក ដែលមានសិទ្ធិស្មើគ្នាលើឆាកអន្តរជាតិ ហើយនេះក៏ជានិមិត្តរូបនៃភាពស្មើគ្នារបស់មនុស្សផងដែរ
- រូបកួរស្រូវពណ៌មាស៧៩គ្រាប់ ទ្រភូគោលផ្នែកខាងឆ្វេង តំណាងឲ្យភាពសម្បូរសប្បាយ ភាពរីកលូតលាស់លើគ្រប់វិស័យ ភាពសុខដុមរមនា និងសុភមង្គលគ្រប់បែបយ៉ាង ដែលឆ្លុះបញ្ចាំងនូវភាពរីកចម្រើនឥតឈប់ឈរ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩
- រូបធាងស្លឹកអូលីវពណ៌បៃតង ៧ទង ទ្រភូគោលផ្នែកខាងស្តាំ តំណាងឲ្យការចង់បានសុខសន្តិភាពជាមួយប្រទេសនានាទាំងអស់ ក្នុងពិភពលោកដែលស្រលាញ់លទ្ធិប្រជាធិបតេយ្យ។ ធាងស្លឹកអូលីវនេះក៏តំណាងផងដែរនូវសេចក្តីយុត្តិធម៌ លើកស្ទួយសិទ្ធិរស់នៅរបស់ប្រជាជនទូទៅ ដោយគ្មានការរើសអើងពណ៌សម្បុរនិងជាតិសាសន៍

ឡើយ ពោលគឺលើកស្ទួយវិស័យសិទ្ធិមនុស្សទូទៅ។ ស្លឹកអូលីវ៧ទង ចង់រំលឹកពីថ្ងៃ ៧មករា ជាថ្ងៃដែលប្រជាជនកម្ពុជាទទួលបានសិទ្ធិរស់រានមានជីវិតមកវិញ។
រូបសញ្ញាដែលមានខ្លឹមសារដូចបានចែងខាងលើជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

មាត្រា ១៨: រូបសញ្ញារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ប្រើក្នុងករណីផ្សេងៗទៀតដោយមានការឯកភាពពីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

មាត្រា ១៩: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានត្រាមូលប្រើសម្រាប់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។
ត្រារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានវណ្ឌពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាល។ ផ្នែកខាងលើរូបប្រាសាទអង្គរវត្តកំពូលបី មានឆ្លាក់អក្សរ "ព្រះរាជាណាចក្រកម្ពុជា" ស្របតាមវណ្ឌ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា" ស្របតាម វណ្ឌ និងនៅចន្លោះរូបទាំងពីរមានរូបផ្កាចន្ទន៍នៅសងខាង។
ត្រាដែលមានខ្លឹមសារដូចបានចែងខាងលើ ជាឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ២០: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២១: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១០១៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២០០ ០០០ ០០០រៀល (ពីររយលានរៀលគត់) ពីជំពូក ៦០ (ការទិញ) និងជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

មាត្រា២.-

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពន្លឺ មុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៩០៧,៦៣ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះកាត់ចេញពី (១) ដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៦៦គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៨៧ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៩៥៥អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១: ត្រូវបានកាត់ដីសរុបទំហំ ៩០៧,៦៣ ហិកតា ក្នុងនោះ (១) ទំហំ ៥,៧៤ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៨៧ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (២) ទំហំ ៩០១,៨៩ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មដីទំហំ ៨៨២,៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២៤,៦៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិគោក ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១, ទី២ និង ទី៣ នៃអនុក្រឹត្យនេះ ។

មាត្រា ២: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៤៦៦គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិគោក ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

មាត្រា ៣: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ៤ នៃអនុក្រឹត្យលេខ....២៥៧ អនក្រ.បក....................ចុះថ្ងៃទី១៦ ខែ....ធ្នូ....ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលផ្ទៃដីសរុបទំហំ ៥៣៣,៣៤ ហិកតា ចេញពីដែនដីកម្រិតព្រៃឈើឆ្នាំ២០០២ និងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ លើផ្ទៃដីទំហំ ៥១៥,២៣ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែងចំនួន ៣២៩ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ១៨,១១ ហិកតា នៅភូមិគោក ឃុំសង្កែសាធប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ



ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ......ចុះថ្ងៃទី......ខែ......ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៩០៧,៦៣ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើជាកម្មសិទ្ធិឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៤៦៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



តារាងចំណុចនិយាមកា

ID	X	Y	ID	X	Y	ID	X	Y
តំបន់ I			42	405796	1292630	86	407108	1294330
1	406783	1294820	43	405791	1292640	87	407163	1294320
2	406767	1294910	44	405850	1292670	88	407123	1294180
3	406774	1294920	45	405923	1292690	89	407069	1294170
4	406800	1294910	46	405975	1292710	90	407059	1294100
5	406856	1294950	47	406025	1292700	91	407090	1294090
6	406866	1294950	48	406031	1292690	92	407122	1294060
7	406848	1295140	49	406167	1292730	93	407210	1294040
8	406896	1295180	50	406208	1292730	94	407223	1293990
9	406945	1295130	51	406298	1292770	95	407346	1293950
10	406934	1295030	52	406314	1292790	96	407618	1293910
11	406999	1294990	53	406297	1292830	97	407608	1293800
12	407001	1294950	54	406384	1292900	98	407593	1293680
13	407038	1294950	55	406399	1292910	99	407542	1293560
14	407040	1294900	56	406418	1292880	100	407435	1293550
15	406918	1294860	57	406473	1292860	101	407360	1293460
តំបន់ II			58	406489	1292870	102	407340	1293300
16	407156	1294770	59	406509	1292870	103	407241	1293130
17	407202	1294790	60	406520	1292860	104	407217	1293140
18	407283	1294780	61	406542	1292920	105	407143	1293120
19	407304	1294740	62	406544	1293040	106	407018	1292940
20	407294	1294650	63	406540	1293090	107	407036	1292910
21	407258	1294610	64	406574	1293130	108	407033	1292860
22	407243	1294570	65	406642	1293160	109	407016	1292810
23	407211	1294570	66	406726	1293190	110	406994	1292760
24	407190	1294560	67	406785	1293200	111	406970	1292710
25	407139	1294560	68	406819	1293180	112	406964	1292650
តំបន់ III			69	406953	1293070	113	406857	1292350
26	406674	1291490	70	406946	1293080	114	406826	1292320
27	406556	1291560	71	406919	1293150	115	406802	1292290
28	406045	1291970	72	406905	1293160	116	406742	1292260
29	405771	1292120	73	406862	1293220	117	406700	1292200
30	405524	1292160	74	406846	1293280	118	406683	1292170
31	405526	1292190	75	406853	1293330	119	406652	1292200
32	405564	1292250	76	406811	1293560	120	406628	1292150
33	405562	1292290	77	406863	1293650	121	406689	1292120
34	405574	1292330	78	406983	1293710	122	406706	1292150
35	405587	1292360	79	407002	1293770	123	406800	1292150
36	405650	1292420	80	407029	1293870	124	406836	1292110
37	405684	1292440	81	407013	1293890	125	406921	1292100
38	405702	1292480	82	407019	1294000	126	406960	1292090
39	405745	1292560	83	407046	1294100	127	406928	1291790
40	405758	1292610	84	407069	1294360	128	406924	1291660
41	405782	1292610	85	407104	1294370	129	406848	1291430



ឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យលេខ...៥៧៧...អនក្រ.បក.............ចុះថ្ងៃទី...៤...ខែ...ធ្នូ......ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៩០៧,៦៣ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៤៦៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



តារាងចំណុចនិយាមកា

ID	X	Y	ID	X	Y
កំបន់ I			42	406591	1298180
1	405872	1296890	43	406791	1297970
2	405924	1296890	44	406792	1297890
3	405934	1296860	45	406753	1297750
4	405924	1296780	46	406679	1297680
5	405980	1296720	47	406575	1297630
6	406032	1296700	48	406516	1297630
7	406074	1296710	49	406277	1297700
8	406102	1296690	50	406161	1297730
9	406108	1296680	51	406144	1297670
10	406129	1296630	52	406069	1297620
11	406110	1296590	53	406044	1297500
12	406121	1296550	54	405998	1297400
13	406056	1296540	55	405900	1297320
14	406030	1296550	56	405776	1297290
15	405986	1296580	57	405674	1297310
16	405946	1296610	58	405596	1297340
17	405895	1296640	59	405615	1297430
18	405854	1296700	60	405596	1297490
19	405879	1296770	61	405495	1297570
កំបន់ II			62	405358	1297620
20	405421	1299660	63	405298	1297690
21	405431	1299480	64	405409	1297970
22	405533	1299330	65	405343	1298000
23	405673	1299130	66	405285	1298060
24	405747	1299020	67	405145	1298210
25	405747	1299020	68	405184	1298300
26	405748	1299020	69	405274	1298340
27	405748	1299020	70	405464	1298380
28	405748	1299020	71	405654	1298410
29	405858	1298970	72	405759	1298420
30	406018	1298880	73	405819	1298410
31	406333	1298830	74	405807	1298470
32	406334	1298830	75	405737	1298560
33	406405	1298670	76	405693	1298650
34	406370	1298560	77	405576	1298780
35	406240	1298490	78	405467	1299050
36	406142	1298510	79	405403	1299120
37	406030	1298500	80	405227	1299040
38	405993	1298450	81	405124	1299130
39	406197	1298410	82	405112	1299450
40	406410	1298310	83	405184	1299590
41	406531	1298200			



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៣០៥,៣២ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពី (១) ដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣០គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៨៦ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៨៨ អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១: ត្រូវបានកាត់ដីសរុបទំហំ ៣០៥,៣២ហិកតា ក្នុងនោះ (១) ទំហំ ២៩៤,៤៨ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៨៦ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និង (២) ទំហំ ១០,៨៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មដីទំហំ ២៩១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ១៤,៣២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិតាគុក ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៣០ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាគុក ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

មាត្រា ៣: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៩ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ........អនក្រ.បក..........................ចុះថ្ងៃទី......ខែ......ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ៣០៥,៣២ ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២៩១,០០ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងចំនួន ២៣០ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ១៤,៣២ ហិកតា នៅភូមិតាគុក ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ



តារាងចំណុចនិយាមកា

ID	X	Y	ID	X	Y	ID	X	Y
1	407415	1307130	59	409399	1305940	117	409319	1305050
2	407423	1307120	60	409407	1305940	118	409271	1305060
3	407502	1307040	61	409468	1305880	119	409116	1305080
4	407507	1307030	62	409466	1305850	120	409051	1305080
5	407573	1306950	63	409452	1305850	121	409050	1305190
6	407585	1306930	64	409426	1305830	122	409020	1305190
7	407721	1306940	65	409403	1305830	123	408905	1305210
8	407806	1306900	66	409384	1305820	124	408835	1305210
9	407953	1306870	67	409365	1305800	125	408835	1305230
10	407998	1306890	68	409354	1305800	126	408744	1305220
11	408054	1306880	69	409348	1305770	127	408733	1305230
12	408139	1306870	70	409380	1305760	128	408585	1305220
13	408197	1306860	71	409363	1305710	129	408582	1305250
14	408200	1306860	72	409366	1305680	130	408567	1305250
15	408202	1306840	73	409299	1305520	131	408562	1305300
16	408216	1306840	74	409304	1305510	132	408563	1305340
17	408220	1306810	75	409337	1305500	133	408507	1305340
18	408222	1306780	76	409376	1305450	134	408498	1305320
19	408231	1306790	77	409393	1305440	135	408302	1305340
20	408392	1306770	78	409413	1305420	136	408293	1305470
21	408520	1306760	79	409421	1305360	137	408139	1305440
22	408518	1306780	80	409432	1305350	138	408139	1305400
23	408558	1306790	81	409442	1305330	139	408011	1305400
24	408604	1306790	82	409498	1305320	140	408028	1305500
25	408606	1306790	83	409496	1305310	141	408141	1305470
26	408643	1306800	84	409461	1305270	142	408145	1305640
27	408644	1306800	85	409450	1305240	143	408137	1305610
28	408647	1306770	86	409442	1305220	144	408115	1305570
29	408652	1306750	87	409437	1305220	145	407923	1305560
30	408704	1306750	88	409445	1305190	146	407927	1305460
31	408844	1306750	89	409475	1305180	147	407798	1305460
32	408883	1306750	90	409481	1305190	148	407798	1305500
33	408939	1306750	91	409504	1305210	149	407690	1305490
34	408970	1306740	92	409509	1305220	150	407654	1305490
35	409099	1306750	93	409565	1305200	151	407643	1305460
36	409100	1306740	94	409563	1305180	152	407609	1305460
37	409250	1306700	95	409552	1305180	153	407524	1305500
38	409311	1306670	96	409551	1305150	154	407542	1305570
39	409293	1306610	97	409549	1305130	155	407559	1305590
40	409272	1306610	98	409546	1305120	156	407615	1305660
41	409258	1306590	99	409564	1305110	157	407628	1305720
42	409252	1306530	100	409570	1305110	158	407589	1305750
43	409274	1306520	101	409621	1305140	159	407565	1305860
44	409338	1306500	102	409631	1305120	160	407522	1306040
45	409359	1306490	103	409640	1305080	161	407520	1306060
46	409408	1306450	104	409674	1305070	162	407466	1306080
47	409386	1306360	105	409693	1305060	163	407439	1306090
48	409399	1306300	106	409698	1305050	164	407231	1306000
49	409392	1306230	107	409695	1305010	165	407215	1306130
50	409411	1306190	108	409680	1305010	166	407386	1306210
51	409466	1306140	109	409648	1305020	167	407279	1306210
52	409474	1306110	110	409624	1305020	168	407297	1306400
53	409494	1306090	111	409574	1305020	169	407254	1306640
54	409459	1306070	112	409507	1305030	170	407253	1306690
55	409456	1306040	113	409493	1305030	171	407261	1306800
56	409447	1305950	114	409448	1305040	172	407367	1307130
57	409416	1305970	115	409423	1305040	173	407369	1307130
58	409400	1305960	116	409393	1305040			

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦៤ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយ ការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ~

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នាយនគរបាល និងនាយនគរបាលរង ចំនួន ៦៧៨ នាក់ នៃក្រសួងមហាផ្ទៃ ដែលមានស្នាដៃល្អ ក្នុងកិច្ចប្រតិបត្តិការ ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គមជូនប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោមៈ

ក-មេដាយមាស ការងារៈ

១-លោកឧត្តមសេនីយ៍ត្រី	ម៉ៅ	តារា	អត្តលេខ ០៤១០	អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
២-លោកឧត្តមសេនីយ៍ត្រី	សៀង	អូន	អត្តលេខ ០៦៣៧	អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
៣-លោកឧត្តមសេនីយ៍ត្រី	កើត	ប៊ុនណា	អត្តលេខ ០១២៧៥	អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
